# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ បង្ហាញពីស្ថានភាពសេដ្ឋកិច្ចនៃប្រទេសមានសេដ្ឋកិច្ចជឿនលឿនមួយចំនួនក្នុងពិភពលោក និង ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននៅអាស៊ីខាងកើត នៅត្រីមាសទី៣ ឆ្នាំ២០០៨ ។

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទី៣ ឆ្នាំ២០០៨ ផសស ពិតពីមួយឆ្នាំទៅមួយឆ្នាំនៅសហរដ្ឋអាមេរិក កើន 0,៥% ដែលបង្ហាញពីការធ្លាក់ចុះកំនើនយ៉ាងខ្លាំង ។ ការធ្លាក់ចុះនេះបណ្តាលមកពីការរួមចំនែកអវិជ្ជមាននៃចំនាយប្រើប្រាស់ផ្ទាល់ខ្លួន (៣,៨%), វិនិយោគលើទ្រព្យសកម្មជាប់លាប់ និងលើគ្រឿងបរិក្ខារនិងសូហ្វវែរ ។ កំណើនសេដ្ឋកិច្ចយឺតក៏មានជាក់ស្តែងនៅតំបន់អឺរ៉ូដែរ ដោយកំនើន ផសស ប្រចាំឆ្នាំធ្លាក់ចុះមកត្រឹម 0,៦% នៅត្រីមាសនេះ ។ ការចុះខ្សោយនៃការនាំចេញសុទ្ធ និងចំណាយវិនិយោគ ជាឧបសគ្គចំបងដល់កំនើនសេដ្ឋកិច្ច ។ ក្នុងត្រីមាសនេះដែរ កំនើន ផសស ពិតនៅជប៉ុន មានតួលេខធ្លាក់ទាបបំផុតដល់ -0,៥% ដែលបញ្ជាក់ពីការធ្លាក់ចុះសេដ្ឋកិច្ចយ៉ាងខ្លាំង ។ មូលហេតុចំបងនៃការធ្លាក់ចុះបែបនេះ គឺ ការថយចុះតំរូវការពីប្រទេសក្រៅ ដែលបណ្តាលឱ្យមានការកាត់បន្ថយ វិនិយោគ និងផលិតកម្មរបស់ក្រុមហ៊ុន ។

នៅត្រីមាសទី៣ នេះដែរ កំនើន ផសស ពិតនៅចិន បន្តថយចុះមកត្រឹម ៩% ដែលជាកំនើនយឺតបំផុត គិតចាប់ពីត្រីមាសទី២ ឆ្នាំ២០០៣ ។ ការធ្លាក់ចុះក្នុងផ្នែកនាំចេញដែលជាសសរទ្រូងដ៏សំខាន់មួយនៃការលូតលាស់ វាផុសចេញពីការធ្លាក់ចុះសេដ្ឋកិច្ច និងការរីករាលផ្នែកហិរញ្ញវត្ថុនៅលើពិភពលោក ហើយវាជាកត្តាដ៏សំខាន់ដែលនាំឱ្យមានការលូតលាស់យឺតនេះ ។ ផសស ពិតសរុបនៅកូរ៉េខាងត្បូងកើនឡើងយឺតបានត្រឹម ៣,៨% ធៀបនឹងឆ្នាំមុន ដែលបណ្តាលមកពីការរួមចុះក្នុងឧស្សាហកម្មផលិតកម្មដូចជា ការផលិតរថយន្ត អង្គធាតុពាក់កណ្តាលចំលង និងកុំព្យូទ័រ ។ កំនើន ផសស ពិតរយៈពេល ១២ខែ របស់ហុងកុង និង តៃវ៉ាន់ ធ្លាក់ចុះយ៉ាងខ្លាំងពី ៤,២% និង ៤,៣% នៅត្រីមាសទី២ មកត្រឹម ១,៧% និង -១,0% នៅត្រីមាសទី៣ ។ ការប្រែប្រួលកំនើន ផសស នៅហុងកុងបណ្តាលមកពីការធ្លាក់ចុះក្នុងផ្នែកនាំចេញ និងតំរូវការក្នុងស្រុក រីឯការធ្លាក់ចុះនៅតៃវ៉ាន់ គឺមកពី ការថយចុះតំរូវការក្នុងស្រុក និងការថយចុះយ៉ាងខ្លាំងនៃការនាំចេញ ។

នៅត្រីមាសទី៣ ឆ្នាំ២០០៨ កំនើន ផសស ពិតប្រចាំឆ្នាំនៅម៉ាឡេស៊ី គឺ ៤,៧% ធៀបនឹង ៦,៣% នៅត្រីមាសមុន ។ ការថយចុះនេះ បណ្តាលមកពីការលូតលាស់យឺតក្នុងវិស័យកសិកម្ម រ៉ែ និងផលិតកម្ម ។កំនើន ផសស ពិតនៅសិង្ហបុរី ក្នុងរយៈពេល១២ខែមុនបានរួមចុះអស់ ២ត្រីមាសជាបន្តបន្ទាប់ មកត្រឹម -0,៦% ដែលបង្កមកពី កំនើនអវិជ្ជមានក្នុងវិស័យផលិតកម្ម (-១១,៤%) និងកំនើនយឺតក្នុងវិស័យសំណង់ (១២,៨% ធៀបនឹង ១៩,៨% នៅត្រីមាសមុន) ។ កំនើន ផសស ពិតនៅថៃ បន្តនៅខ្លាំងដដែល គឺ ៣,៩% ទោះថយចុះបន្តិច ធៀបនឹងកំរិត ៥,៣% នៅត្រីមាសទី២ ក្តី ។ កំនើនយឺតជាងមុននេះ បណ្តាលមកពី ការធ្លាក់កំនើនក្នុងផ្នែកផលិតកម្មផលដំណាំ សត្វចិញ្ចឹម វត្ថុធាតុដើម និងទំនិញមូលធន ដូចជា យានយន្ត និងគ្រឿងម៉ាស៊ីនប្រើក្នុងការិយាល័យ ជាដើម ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៣ ឆ្នាំ២០០៨ កំនើនថ្លៃទំនិញប្រើប្រាស់សរុបពីមួយឆ្នាំទៅមួយឆ្នាំនៅសហរដ្ឋអាមេរិក គឺ ៥,៣% ដែលជាតួលេខខ្ពស់បំផុតគិតតាំងពីឆ្នាំ២០០៣ បើទោះជាថាមពលបានចុះថ្លៃយ៉ាងខ្លាំងតាំងពីពាក់កណ្តាលខែកក្កដាមកក្តី ។ អតិផរណានៅតំបន់អឺរ៉ូនៅតែមានកំរិតខ្ពស់ គឺ ៣,៨% ធៀបនឹង ១,៩% នៅត្រីមាសដូចគ្នាឆ្នាំមុន ដែលបណ្តាលមកពី ការឡើងថ្លៃជាបន្តបន្ទាប់នៃ ម្ហូបអាហារ និង សេវាកម្ម ។ ថ្លៃទំនិញប្រើប្រាស់សរុបក្នុងរយៈពេល ១២ខែ នៅជប៉ុនកើនឡើង ២,២% ដែលជាអត្រាកំនើនខ្ពស់បំផុត ក្នុងរយៈមួយទសវត្សរ៍ ហើយបង្កចេញពីការឡើងថ្លៃមួយជាពីរនៃការដឹកជញ្ជូនជាឯកជន ។

នៅត្រីមាសទី៣ ប្រាក់ដុល្លារUS ធ្លាក់ថ្លៃបន្តិចទល់នឹង ប្រាក់យ៉ុនចិន ដោយប្តូរបាន ៦,៨យ៉ុន/ដុល្លារUS ប៉ុន្តែវាឡើងថ្លៃទល់នឹងប្រាក់ដុល្លារសិង្ហបុរី (៤,៤%), ប្រាក់អឺរ៉ូ (១០,៩%), ប្រាក់វ៉ុនកូរ៉េខាងត្បូង (១៨,៥%) និង ប្រាក់ដុល្លារតៃវ៉ាន់ (២,៥%) ។ ប្រាក់ ដុល្លារUS នៅថេរទល់នឹង ប្រាក់ដុល្លារហុងកុង និង ប្រាក់យ៉េនជប៉ុន ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី៣ ឆ្នាំ២០០៨ ថ្លៃផលិតផលកសិកម្មជាច្រើននៅលើទីផ្សារអន្តរជាតិ បង្ហាញនូវនិទស្សន៍មិនល្អមួយ សំរាប់ផលិតករ ។ ប្រេងឆា (នៅអឺរ៉ុបខាងពាយព្យ) និងអង្ករ (Thai 100% B) ធ្លាក់ថ្លៃយ៉ាងខ្លាំងអស់ ១២,៧% និង ២១,៦% ប៉ុន្តែ ពោត (US លេខ២) និងសណ្តែកសៀង (US លេខ១) ឡើងថ្លៃ ៧,១% និង ១០,៣% ។ សាំងឡើងថ្លៃបន្តិចដល់ ៨១,៣សេន/លីត្រ ប៉ុន្តែប្រេងឆៅចុះថ្លៃអស់ ១,៨% ដល់ ១១៥,៣0ដុល្លារUS/ធុង ហើយម៉ាស៊ូតចុះថ្លៃអស់ ៧,២% ដល់ ៨៨,៤សេន/លីត្រ ។

*រៀបរៀងដោយ*
*សាំង ច័ន្ទហង្ស*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-០៨ ( កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q3 | Q4 | 2008 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 7 | 7.7 | 13.4 | 10.6 | 10.2 | 8.1 | 13.6 | - | - | - |
| ឥណ្ឌូនេស៊ី | 4.9 | 5.1 | 5.6 | 5.4 | 6.3 | 6.5 | 6.5 | 6.3 | 6.4 | 6.1 |
| ម៉ាឡេស៊ី | 5.4 | 7 | 5.2 | 5.9 | 6.3 | 6.7 | 7.3 | 7.1 | 6.3 | 4.7 |
| សិង្ហបុរី | 1.4 | 8.5 | 5.7 | 7.7 | 7.7 | 8.9 | 6.0 | 7.2 | 1.9 | -0.6 |
| ថៃ | 6.9 | 6 | 4.5 | 4.8 | 4.9 | 4.8 | 5.7 | 6.0 | 5.3 | 3.9 |
| វៀតណាម | 7 | 7.5 | 8.4 | 8.1 | 8.5 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 9.9 | 9.5 | 9.6 | 10.5 | 11.9 | 11.4 | 11.2 | 10.6 | 10.1 | 9.0 |
| ហុងកុង | 3.2 | 8.3 | 6.5 | 6.6 | 6.4 | 6.2 | 6.7 | 6.8 | 4.2 | 1.7 |
| កូរ៉េខាងត្បូង | 3 | 4.7 | 4.7 | 5.0 | 4.9 | 5.2 | 5.7 | 5.7 | 4.8 | 3.8 |
| តៃវ៉ាន់ | 3.1 | 5.7 | 4.1 | 4.6 | 5.2 | 6.9 | 6.4 | 6.4 | 4.3 | -1.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 0.5 | 1.8 | 1.5 | 2.7 | 2.9 | 2.7 | 2.2 | 2.2 | 1.4 | 0.6 |
| ជប៉ុន | 2.6 | 3.4 | 2.5 | 2.1 | 2.0 | 1.9 | 2.0 | 1.3 | 1.0 | -0.5 |
| សហរដ្ឋអាមេរិក | 3.1 | 4.4 | 3.7 | 3.3 | 2.2 | 4.9 | 2.5 | 2.5 | 2.8 | 0.5 |

*Sources: International Monetary Fund, Economist and countries' statistic offices*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-២០០៨ ( កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q3 | Q4 | 2008 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 1.2 | 4.0 | 5.8 | 4.7 | 10.5 | 6.0 | 9.6 | 16.5 | 24.9 | 21.7 |
| ឥណ្ឌូនេស៊ី | 8.3 | 8.3 | 10.5 | 13.4 | 6.4 | 6.5 | 6.7 | 7.6 | 10.1 | 11.9 |
| ម៉ាឡេស៊ី | 1.1 | 1.6 | 3.1 | 3.7 | 2.0 | 1.8 | 2.2 | 2.6 | 4.8 | 8.4 |
| សិង្ហបុរី | 0.5 | 1.7 | 0.5 | 1.0 | 2.1 | 2.7 | 4.1 | 6.6 | 7.5 | 6.5 |
| ថៃ | 1.8 | 2.7 | 4.5 | 4.7 | 2.2 | 1.7 | 2.9 | 5.0 | 7.7 | 7.2 |
| វៀតណាម | 3.1 | 7.8 | 8.2 | 7.7 | 8.3 | 8.6 | 10.7 | 16.4 | 24.4 | 29.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 1.2 | 3.9 | 1.8 | 1.5 | 4.8 | 6.1 | 6.6 | 8.0 | 7.8 | 5.3 |
| ហុងកុង | -2.6 | -0.4 | 1.1 | 2.2 | 2.0 | 1.6 | 3.5 | 4.6 | 5.7 | 4.6 |
| កូរ៉េខាងត្បូង | 3.5 | 3.5 | 2.8 | 2.4 | 2.5 | 2.3 | 3.3 | 3.7 | 4.8 | 5.5 |
| តៃវ៉ាន់ | -0.3 | 1.6 | 2.3 | 0.6 | 1.8 | 1.4 | 4.5 | 2.3 | 4.2 | 4.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 2.2 | 2.2 | 2.1 | 2.1 | 1.9 | 2.9 | 3.4 | 3.8 | 3.8 |
| ជប៉ុន | -0.3 | Nil | -0.3 | 0.5 | 0.1 | -0.1 | 0.5 | 1.0 | 1.4 | 2.2 |
| សហរដ្ឋអាមេរិក | 2.3 | 2.7 | 3.4 | 3.2 | 2.9 | 2.4 | 3.9 | 4.1 | 4.4 | 5.3 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-២០០៨ ( មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q3 | Q4 | 2008 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា ( រៀល) | 3973 | 4016.3 | 4092.5 | 4103.2 | 4062.7 | 4078 | 4026 | 3995.3 | 4030.3 | 4117.4 |
| ឥណ្ឌូនេស៊ី ( រូពីយ៉ា) | 8577 | 8938 | 9705 | 9134 | 9419 | 9257.8 | 9246.3 | 9248.2 | 9265.3 | 9216.3 |
| ម៉ាឡេស៊ី ( រីងហ្គិត) | 3.80 | 3.80 | 3.79 | 3.67 | 3.31 | 3.46 | 3.35 | 3.22 | 3.21 | 3.37 |
| សិង្ហបុរី ( ដុល្លារសិង្ហបុរី) | 1.74 | 1.69 | 1.66 | 1.59 | 1.51 | 1.52 | 1.45 | 1.41 | 1.37 | 1.43 |
| ថៃ ( បាត) | 41.5 | 40.2 | 40.2 | 37.9 | 32.22 | 31.4 | 33.87 | 32.37 | 32.25 | 34.0 |
| វៀតណាម ( ដុង) | 15,510 | 15,777 | 15,859 | 15,994 | 16,030 | 16,206 | 16,084 | 15,896 | 16,881 | 16,517 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន ( យ៉ន់) | 8.28 | 8.28 | 8.19 | 7.97 | 8.03 | 7.55 | 7.43 | 7.16 | 6.96 | 6.82 |
| ហុងកុង ( ដុល្លារហុងកុង) | 7.78 | 7.79 | 7.78 | 7.77 | 7.8 | 7.81 | 7.77 | 7.79 | 7.80 | 7.77 |
| កូរ៉េខាងត្បូង ( វ៉ុន) | 1192 | 1145 | 1024 | 955 | 929.04 | 927 | 921.23 | 955.89 | 1018.84 | 1207.0 |
| តៃវ៉ាន់ ( ដុល្លារតៃវ៉ាន់-NT$) | 34.4 | 33.6 | 32.1 | 32.5 | 32.85 | 32.9 | 32.4 | 31.52 | 30.45 | 31.20 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ ( អឺរ៉ូ) | 0.89 | 0.80 | 0.80 | 0.80 | 0.7 | 0.73 | 0.69 | 0.7 | 0.64 | 0.71 |
| ជប៉ុន ( យ៉េន) | 115.9 | 108.2 | 110.2 | 116.4 | 117.8 | 117.7 | 113.07 | 105.2 | 104.53 | 104.03 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៣-២០០៨ ( មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q3 | Q4 | 2008 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|
| ពោត (US No. 2) - US ($/តោន) | 95.42 | 110.65 | 89.19 | 111.04 | 149.08 | 139.81 | 156.9 | 198.39 | 238.03 | 254.99 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 402.03 | 427.47 | 381.32 | 433.85 | 707.68 | 745.86 | 841.39 | 1048.49 | 1086.89 | 949.03 |
| អង្ករ (Thai 100%B) - បាងកក ($/តោន) | 182.22 | 221.67 | 262.88 | 282.00 | 305.36 | 304.75 | 323.92 | 444.43 | 839.58 | 657.88 |
| សណ្តែកសៀង (US No. 1) - US ($/តោន) | 218.86 | 262.03 | 224.25 | 213.88 | 294.59 | 299.99 | 366.59 | 449.64 | 479.97 | 529.30 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 26.8 | 33.5 | 50.14 | 61.58 | 69.25 | 72.48 | 82.88 | 93.77 | 117.48 | 115.30 |
| សាំង - US Gulf Coast ( សេន/លីត្រ) | 23 | 30.9 | 42.19 | 47.70 | 53.58 | 55.49 | 59.48 | 64.21 | 80.90 | 81.27 |
| ម៉ាស៊ូត ( ស្ពាន់ធ័រតិច លេខ២) - US Gulf Coast ( សេន/លីត្រ) | 21.63 | 29.48 | 44.35 | 51.35 | 55.51 | 56.62 | 66.54 | 73.99 | 95.37 | 88.46 |

*Sources: Food and Agriculture Organisation and US Energy Information Administration*